**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកអគ្គរដ្ឋទូតសហព័ន្ធស្វីស ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**លោកជំទាវ** Helene Budliger Artieda ឯកអគ្គរដ្ឋទូតថ្មីនៃសហព័ន្ធស្វីស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងអបអរសាទរយ៉ាងកក់ក្តៅដល់ **លោកជំទាវ** Helene Budliger Artieda ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីនៃសហព័ន្ធស្វីស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងបានសម្តែងការជឿជាក់ថា ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនឹងត្រូវបានពង្រឹងបន្ថែមទៀត ទាំងក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ក្នុងអាណត្តិការងាររបស់លោកជំទាវ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសំដែងការពេញចិត្តចំពោះការរីកចំរើននៃទំនាក់ទំនងរវាងប្រទេសទាំងពីរតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ និងយន្តការពិគ្រោះយោបល់ទ្វេរភាគី ដែលកន្លងមកមានការជួបប្រជុំគ្នាចំនួនពីរដងរួចមកហើយ ដោយបានពិភាក្សាលើការពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើន ។

ជាការឆ្លើយតប **លោកជំទាវ ឯកអគ្គរដ្ឋទូត** បានសម្តែងនូវសេចក្តីរីករាយដែលបានទទួលការតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា ក្នុងដំណាក់កាលដែលទំនាក់ទំនងរវាងប្រទេសទាំងពីរកំពុងមានការរីកចម្រើនគួរកត់សម្គាល់។ លោកជំទាវបានរំលឹកផងដែរថា ប្រទេសទាំងពីរមានទំនាក់ទំនងការទូតតាំងពីឆ្នាំ១៩៦៣ ហើយ **លោកជំទាវ** បានបញ្ជាក់ថា នឹងខិតខំធ្វើអោយទំនាក់ទំនងរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំនិងស៊ីជម្រៅបន្ថែមទៀត។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **លោកជំទាវ ឯកអគ្គរដ្ឋទូត** បានពិភាក្សាអំពីការជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យមួយចំនួន មានជាអាទិ៍ ពាណិជ្ជកម្ម វិនិយោគ កសិកម្ម ទេសចរណ៍ សុខាភិបាល សន្តិសុខស្បៀង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងអភិបាលកិច្ចជាដើម។ នៅក្នុងវិស័យសុខាភិបាល រដ្ឋាភិបាលស្វីសនៅបន្តជួយឧបត្ថម្ភមន្ទីរពេទ្យគន្ធបុប្ផានូវទឹកប្រាក់ចំនួន១២លានហ្វ្រង់ស្វីស

សំរាប់ឆ្នាំ ២០១៩ ដល់២០២១។ ប្រទេសស្វីសបានជួយឧបត្ថម្ភមន្ទីរពេទ្យនេះចាប់តាំងពីឆ្នាំ១៩៩៤ រហូតមកឆ្នាំ២០១៨ នូវទឹកប្រាក់ចំនួន៦០លានហ្វ្រង់ស្វីស។ លើសពីនេះទៅទៀត លោកជំទាវបានសន្យាថា នឹងដឹកនាំវិនិយោគិនធំៗរបស់ស្វីសមកពិនិត្យមើលសក្តានុពលវិនិយោគនៅកម្ពុជា ដើម្បីពង្រីកទំហំវិនិយោគ និងពាណិជ្ជកម្មបន្ថែមទៀត។ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ រដ្ឋាភិបាលស្វីសបានផ្តល់ហិរញ្ញប្បទានដល់យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការតំបន់មេគង្គចំនួនទឹកប្រាក់ ៦១លានហ្វ្រង់ស្វីស សំរាប់ឆ្នាំ២០១៣-២០១៧ និងចំនួន៥០លានហ្វ្រង់ស្វីសសំរាប់ឆ្នាំ២០១៨-២០២១ ហើយប្រទេសស្វីសក៏ជាដៃគូសន្ទនាដោយផ្នែក( Sectoral Dialogue Partner )របស់អាស៊ានផងដែរ។

ឆ្លៀតក្នុងឱកាសនោះផងដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលស្វីសដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា រួមទាំងវិស័យសុខាភិបាល កសិកម្ម ទេសចរណ៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការដោះមីនជាដើមដើម្បីឲ្យកម្ពុជាឈានទៅសម្រេចគោលដៅអស់គ្រាប់មីននៅឆ្នាំ២០២៥៕

------------------